ការចេញផ្សាយព័ត៌មាន

**សន្និសិទសារព័ត៌មានស្តីអំពីកិច្ចសហប្រតិបត្តិការលើការផ្តល់សេវាត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុ រវាងការិយាល័យឥណទានកម្ពុជា (ស៊ីប៊ីស៊ី) និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី**

**ភ្នំពេញ ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៩:** នៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៩ វេលាម៉ោង២រសៀល នៅទីស្នាក់ការកណ្តាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី មានការរៀបចំសន្និសិទសារព័ត៌មានស្តីអំពីកិច្ចសហប្រតិបត្តិការលើការផ្តល់សេវាត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុ រវាងការិយាល័យឥណទានកម្ពុជា (ស៊ីប៊ីស៊ី) និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី បន្ទាប់ពីការចុះអនុស្សារណយោគយល់គ្នារវាងស្ថាប័នទាំងពីរ ក្នុងការដាក់ឱ្យដំណើរការសេវានេះនៅតាមសាខារបស់ អេ អឹម ខេ ចាប់ពីថ្ងៃទី២ ខែមករា ឆ្នាំ ២០១៩ តទៅ។

សន្និសិទសារព័ត៌មាននេះ មានការចូលរួមពី លោក **អឿ សុធារ័ត្ន** ប្រធាននាយកប្រតិបត្តិនៃការិយាល័យឥណទានកម្ពុជា លោក **គា បូរាណ** ប្រធាននាយកប្រតិបត្តិនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ថ្នាក់ដឹកនាំជាន់ខ្ពស់នៃស្ថាប័នទាំងពីរ និង អ្នកសារព័ត៌មាននៅកម្ពុជា។

លោក **អឿ សុធារ័ត្ន** ប្រធាននាយកប្រតិបត្តិនៃការិយាល័យឥណទានកម្ពុជា បានមានប្រសាសន៍ថា "ក្នុងរយៈពេលជាង៦ឆ្នាំនៃប្រតិបត្តិការ ស៊ីប៊ីស៊ីបានចាប់ផ្តើម និងផ្តោតចំបងជាមួយនឹងរបាយការណ៍ឥណទានអតិថិជន ដែលអនុញ្ញាតឱ្យសមាជិករបស់យើងអាចស្វែងយល់ពីអតិថិជនរបស់ពួកគេកាន់តែច្បាស់ និងធ្វើការសម្រេចចិត្តលើការផ្តល់ឥណទានប្រកបដោយប្រសិទ្ធិភាព និងទំនួលខុសត្រូវ។ បន្ថែមពីលើនេះ ប្រព័ន្ធនេះក៏បានជួយដល់អតិថិជនទូទៅ ក្នុងការស្នើសុំ និងស្វែងយល់អំពីព័ត៌មានឥណទានរបស់ពួកគេឱ្យកាន់តែប្រសើរឡើង ដែលនឹងជួយពួកគេក្នុងការត្រៀមខ្លួនសម្រាប់ការស្នើសុំកម្ចី។ មិនតែប៉ុណ្ណោះ ប្រព័ន្ធនេះក៏ចូលរួមចំណែកដល់ស្ថិរភាពនៃវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចផងដែរ។"។

លោកបន្តថា "ដោយមើលឃើញពីសារសំខាន់នៃរបាយការណ៍ឥណទានចំពោះប្រជាជនកម្ពុជា និងដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាជនដែលរស់នៅតាមបណ្តាខេត្ត ទើបការិយាល័យឥណទានកម្ពុជាបានពង្រីកសេវាត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុ ដោយធ្វើកិច្ចសហប្រតិបត្តិអាជីវកម្មជាមួយដៃគូយុទ្ធសាស្ត្រ គឺ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ដែលមានសាខាជាង១៥០ ទូទាំងប្រទេស ក្នុងការផ្តល់សេវាកម្មនេះ ដោយជំហានដំបូងយើងដាក់ឱ្យដំណើរការនៅតាមសាខារបស់ អេ អឹម ខេ ចំនួន៥ ហើយគ្រោងនឹងពង្រីកទូទាំងប្រទេសនៅបំណាច់ឆ្នាំ២០១៩នេះ។"

សេវាត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុ គឺជាសេវាកម្មមួយរបស់ ស៊ីប៊ីស៊ី ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋទូទៅ អាចពិនិត្យមើលរបាយការណ៍ឥណទាន ឬ លទ្ធភាពក្នុងការប្រើប្រាស់ឥណទាន ដោយខ្លួនឯងតាមរយៈភ្នាក់ងារដៃគូយុទ្ធសាស្ត្រ របស់ស៊ីប៊ីស៊ី។ ដើម្បីប្រើប្រាស់សេវាកម្មនេះ អតិថិជនគ្រាន់តែយកអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនច្បាប់ដើម និងមានសុពលភាព ហើយអញ្ជើញទៅកាន់សាខាទាំង៥របស់គ្រឹះស្ថានមីក្រូហិញ្ញវត្ថុ អេ អឹម ខេ ភីអិ

លស៊ី ដូចជា ទីស្នាក់ការកណ្ដាល សាខាខណ្ឌពោធិ៍សែនជ័យ សង្កាត់ចោមចៅ៣ សាខាកំពង់ចាម សាខាខេត្តកណ្ដាល និងសាខាខេត្តសៀមរាប។

លោក **គា មុន្នីណា** ប្រធាននាយកប្រតិបត្តិ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី មានប្រសាសន៍ថា "អេ អឹម ខេ មានក្ដីសោមនស្សរីករាយ ដោយបានចាប់ដៃគូសហប្រតិបត្តិការជាមួយការិយាល័យឥណទានកម្ពុជា (ស៊ីប៊ីស៊ី) ក្នុងការបម្រើសេវាត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុដល់ប្រជាជនកម្ពុជាឱ្យបានរីតតែទូលំទូលាយ តាមរយៈការស្នើសុំត្រួតពិនិត្យរបាយការណ៍ឥណទានផ្ទាល់ខ្លួននៅតាមសាខានៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ។ បច្ចុប្បន្ន អេ អឹម ខេ បានផ្ដល់សេវាទៅដល់អតិថិជនជាង ៧៦ ម៉ឺននាក់ និងមានសាខាគ្រប់ដណ្ដប់គ្រប់ស្រុក និងឃុំ ទូទាំងប្រទេស។ ដូច្នេះសេវាហិរញ្ញវត្ថុមួយនេះនឹងជួយដល់អតិថិជនក្នុងការស្វែងយល់ពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងត្រៀមខ្លួនរួចរាល់ប្រកបដោយការទទួលខុសត្រូវក្នុងការទទួលបានប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ។"

ចាប់ដំណើរការជាផ្លូវការនៅឆ្នាំ ២០១២ ស៊ីប៊ីស៊ីបានបម្រើដល់សមាជិក និងអតិថិជនជាមួយនឹងសេវាកម្មស្នូល គឺរបាយការណ៍ឥណទានអតិថិជន។ ប្រព័ន្ធនេះបានចូលរួមចំណែកជាប្រយោជន៍យ៉ាងច្រើនដល់ភាគីពាក់ព័ន្ធរួមមាន ប្រជាជន ស្ថាប័នហិរញ្ញវត្ថុ និងវិស័យហិរញ្ញវត្ថុ។

## អំពីការិយាល័យឥណទានកម្ពុជា (ស៊ីប៊ីស៊ី)

ការិយាល័យឥណទានកម្ពុជាជាក្រុមហ៊ុនឈានមុខគេក្នុងការផ្ដល់ព័ត៌មានឥណទាន ឧបករណ៍វិភាគ និងរបាយការណ៍ឥណទានជូនដល់ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យា គ្រឹះស្ថានឥណទានជនបទ និងអ្នកប្រើប្រាស់នានាក្នុងព្រះរាជាណាចក្រកម្ពុជា។ គិតត្រឹម ខែមករា ឆ្នាំ២០១៩ ស៊ីប៊ីស៊ីមានសមាជិកចំនួន១៦០ស្ថាប័ន។

ស៊ីស៊ីប៊ីស៊ី ត្រូវបានបង្កើតឡើងក្នុងខែមីនា ឆ្នាំ២០១២ ដោយមានការគាំទ្រពីធនាគារជាតិនៃកម្ពុជា (NBC) សមាគមធនាគារនៃកម្ពុជា (ABC) សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងក្រុមប្រឹក្សាហិរញ្ញវត្ថុអន្តរជាតិ (IFC)។

ស៊ីប៊ីស៊ី ជំរុញឱ្យលំនឹងសេដ្ឋកិច្ចកាន់តែប្រសើរឡើងដោយផ្ដល់ទិន្នន័យទាន់ហេតុការណ៍ និងត្រឹមត្រូវដល់អ្នកប្រើប្រាស់ និងឧស្សាហកម្មដែលជួយក្នុងការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុនៃធុរកិច្ចរបស់ពួកគេ។ យើងជួយធុរកិច្ចក្នុងការគ្រប់គ្រងហានិភ័យនៃឥណទាន ការពារការក្លែងបន្លំ និងការធ្វើសេចក្ដីសម្រេចចិត្តដោយស្វ័យប្រវត្តិ។ ស៊ីប៊ីស៊ី ក៏ជួយបុគ្គលប្រើប្រាស់ក្នុងការត្រួតពិនិត្យរបាយការណ៍ឥណទានរបស់ពួកគាត់ដើម្បីធានាថាពួកគាត់អាចទទួលបានប្រាក់កម្ចី និងហិរញ្ញវត្ថុ និងការពារខ្លួនពីការក្លែងបន្លំអត្តសញ្ញាណ។

## អំពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

អេ អឹម ខេ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលឈានមុខគេលើវិសាលភាពប្រតិបត្តិការ និងចំនួនអតិថិជនប្រាក់កម្ចី។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ អេ អឹម ខេ មានអតិថិជនសរុបចំនួនជាង ៧៦ ម៉ឺននាក់ ជាមួយនឹងផលប័ត្រប្រាក់កម្ចីជាង ២៥២ លានដុល្លារអាមេរិក និងប្រាក់បញ្ញើជាង ១៦០ លានដុល្លារអាមេរិក មានការិយាល័យប្រតិបត្តិការចំនួន ១៥០ កន្លែង និងមានភ្នាក់ងារជាង ៤.០០០ កន្លែងនៅទូទាំងប្រទេស។ អេ អឹម ខេ មានផលិតផល និងសេវាកម្មជាច្រើនកំពុងផ្តល់ជូនអតិថិជនដូចជា៖ សេវាប្រាក់កម្ចី ប្រាក់សន្សំ សេវាផ្ទេរប្រាក់ក្នុង និងក្រៅប្រទេស សេវាទូទាត់វិក្កយបត្រ ធានារ៉ាប់រងខ្នាតតូច ភ្នាក់ងារចល័ត សេវាបើកប្រាក់បៀវត្សរ៍ ម៉ាស៊ីនដក និងដាក់ប្រាក់ដោយស្វ័យប្រវត្តិ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈ៖

| | |
|---|---|
| លោក **ផៃ សុផល**<br>ប្រធានផ្នែកទីផ្សារ, ការិយាល័យឥណទានកម្ពុជា( ស៊ីប៊ីស៊ី )<br>ទូរស័ព្ទ៖ ០៨៦ ៩៩៩ ៧៦០<br>អ៊ីម៉ែល៖ s.phay@creditbureau.com.kh | លោកស្រី **សូរិនច័ន្ទ ស៊ូសាណា**<br>នាយិកាប្រតិបត្តិទីផ្សារ និងទំនាក់ទំនង, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី<br>ទូរស័ព្ទ: ០២៣ ៩៩៣ ០៦២<br>អ៊ីម៉ែល: suzana.sorinchan@amkcambodia.com |